# របាយការណ៍

## សិក្ខាសាលាតំរង់ទិស  និងបណ្តុះបណ្តាល
## ស្តីពីការបង្ការជាវិជ្ជមាននិងការផ្តល់សេវាពន្យា
## កំណើតសំរាប់បុគ្គលិកនៃសេវាព្យាបាលជំងឺឱកាស
## និយម  និងឱសថប្រឆាំងមេរោគអេដស៍
## និងគ្លីនិកសុខភាពគ្រួសារ
## ខេត្តព្រៃវែង

The orientation workshop and training on
Positive Prevention and Birth Spacing for OI/ART and
Family Health Clinic Staffs

Neak Loeung, PRV Province 12-13 September 2011

រៀបចំដោយ | សហការណ៍ដោយ | ឧបត្ថម្ភដោយ

**១,ទីកន្លែង** : សាលប្រជុំនៃមន្ទីរពេទ្យបង្អែក អ្នកលឿង ខេត្តព្រៃវែង

**២,កាលបរិច្ឆេទ** : ថ្ងៃទី ១២-១៣ ខែ កញ្ញា ឆ្នាំ ២០១១

**៣,ឧបត្ថម្ភដោយ** : CHAI

**៤,គោលបំណង** :

- ផ្សព្វផ្សាយពីគោលគំនិតសំខាន់ៗស្តីពី ការបង្ការជាវិជ្ជមាន និង ការផ្តល់សេវាពន្យាកំណើតនៅតាមសេវាព្យាបាលជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ និងគ្លីនិកសុខភាពគ្រួសារ ។

-ផ្តល់ចំណេះដឹង និងជំនាញស្តីពីមធ្យោបាយពន្យាកំណើតដល់បុគ្គលិកដែលបំរើការនៅសេវាOI /ART និង STD ។

- ពិភាក្សា និងរកការឯកភាពគ្នាលើយន្តការនៃការស្នើសុំ និងរបាយការណ៍ស្តីពីការប្រើប្រាស់មធ្យោបាយពន្យាកំណើត និង ការប្រមូលទិន្នន័យសំរាប់តាមដាន ។

**៥,រៀបចំដោយ** មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ និង សហការណ៍ដោយមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

**៧,សកម្មភាព** :

ថ្ងៃទី ១ ទី ១២ ខែ កញ្ញា ឆ្នាំ ២០១១

<u>សមាសភាពគណៈអធិបតី:</u>

១, លោកសាស្រ្តាចារ្យ **កេត លីសុត្ថា** អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក

២,លោកវេជ្ជ, **សេង វុធី** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើប្បែក និង កាមរោគ

៣,លោកវេជ្ជ, **ញ៉ឹក ឱមណូរ៉ា** អនុប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង

<u>សមាសភាពចូលរួម:</u>

| | |
|---|---|
| -មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ | ចំនួន ០៩ នាក់ |
| -មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក | ចំនួន ០២ នាក់ |
| -មន្ទីរសុខាភិបាលខេត្ត ព្រៃវែង | ចំនួន ០៤ នាក់ |
| -ស្រុកប្រតិបត្តិ អ្នកលឿង | ចំនួន ០៥ នាក់ |
| -មន្ទីរពេទ្យបង្អែក អ្នកលឿង | ចំនួន ១៧ នាក់ |
| -អង្គការក្រៅរដ្ឋាភិបាល: WOMEN and MHSS | ចំនួន ០៧ នាក់ |

-មតិស្វាគមន៍ដោយលោកវេជ្ជ **ញ៉ឹក ឱមណូរា** អនុប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង

-ចំណាប់អារម្មណ៍របស់លោកវេជ្ជ **សេង វុធី** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និង កាមរោគ ( មជអសក)

-មតិសំណេះសំណាល និង ការប្រកាសបើកដោយ លោកសាស្ត្រាចារ្យ **កេត លីសុវណ្ណា** តំណាងមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក

-ការបង្ហាញពីកម្មវិធី និង គោលបំណងដោយវេជ្ជ សេង វុធី មន្ត្រី នៃមជអសក

-ការបង្ហាញពីបច្ចុប្បន្នភាពនៃស្ថានភាពមេរោគអេដស៍នៅប្រទេសកម្ពុជា ដោយវេជ្ជ ទូច សារុន

-ទស្សនៈស្តីពីការបង្ការជាវិជ្ជមានចំពោះមេរោគអេដស៍ ដោយវេជ្ជ សេង វុធី

-ការប្រើប្រាស់ស្រោមអនាម័យ និង ជំហាននៃការប្រើប្រាស់ស្រោមអនាម័យអោយបានត្រឹមត្រូវបង្ហាញដោយវេជ្ជ **ទូច សារុន**

-ការបង្ហាញពីទំរង់របាយការណ៍ យន្តការបញ្ជូនអ្នកជំងឺក្នុងមន្ទីរពេទ្យ និង ពិភាក្សាពីការបំពេញទំរង់របាយការណ៍ដោយលោក **ផាត់ វាសនា** មន្ត្រីគ្រប់គ្រងទិន្នន័យនៃ មជអសក និង សំរបសំរួលដោយវេជ្ជ **ង៉ែត បុត្រា** មន្ត្រីនៃ មជអសក។

ថ្ងៃទី ២ ទី ១៣ ខែ កញ្ញា ឆ្នាំ ២០១១

-គោលការណ៍គ្រឹះនៃការពន្យាកំណើត និង សិទ្ធិរបស់អ្នកជំងឺក្នុងការទទួលសេវា បង្ហាញដោយលោកស្រី **សោម សម្ផស្ស** មន្ត្រីនៃកម្មវិធីគាំពារមាតា និងទារកខេត្តព្រៃវែង និង សំរបសំរួលដោយលោកវេជ្ជ **ទូច សារុន** មន្ត្រី មជអសក និងនិយមន័យ នៃការពន្យាកំណើត និងប្រព័ន្ធការពន្យាកំណើត ។

-ការប្រើប្រាស់ឱសថពន្យាកំណើតគ្រាប់ដោយលេបរួមមាន: Oral Contraceptive (COC and Emergency Pill, Oral contraceptive POP និង ការប្រើប្រាស់ឱសថពន្យាកំណើតដោយចាក់បង្ហាញដោយលោកស្រី **ខេន ណាវី** សំរបសំរួលដោយលោកវេជ្ជ សេង វុធី ។

-ការបំពេញទំរង់របាយការណ៍ពន្យាកំណើត និងទំរង់ផ្សេងៗទាក់ទងនឹងការឱសថពន្យាកំណើតបង្ហាញដោយលោកស្រី **សោម សម្ភស្ស** មន្ត្រីនៃកម្មវិធីគាំពារមាតា និងទារកខេត្ត ព្រៃវែង និង សំរបសំរួលដោយលោក វេជ្ជ **ទូច សារុន** មន្ត្រី មជអសក។

**៨,ចំណុចល្អជាវិជ្ជមាន:**

- មណ្ឌលសុខភាពនៅជិតមន្ទីរពេទ្យខេត្តព្រៃវែងដែលបង្កលក្ខណ:ងាយស្រួលដល់ការផ្តល់ឱសថ និង មធ្យោបាយពន្យាកំណើតដល់ក្រុម OI/ART
- ស្ត្រីទូទៅមានផ្ទៃពោះរំពឹងទុកមាន: ៤៩៤៧ នាក់ក្នុង មួយឆ្នាំ ២០១១។ លទ្ធផល ANC1 មកពិនិត្យរួមមាន ១១១៥នាក់ ក្នុង ខែសីហា ២០១១។
- របាយការណ៍ត្រីមាសទី ២ ឆ្នាំ២០១១ របស់មន្ទីរពេទ្យបង្អែកអ្នកលឿងរួមមាន: ស្ត្រីផ្ទុកមេរោគអេដស៍រួមមានសរុប ៧៣៩នាក់ (OI=93 cases and ART=646 cases)។
- មានការបញ្ជូនស្ត្រីមានផ្ទៃពោះសង្ស័យ ពីសហគមន៍ ដោយក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះដោយ អង្គការ WOMEN,MHSS based of link Response approach.
- មានការសហការណ៍ល្អរវាងផ្នែកគាំពារមាតា និងទារកខេត្ត និង កម្មវិធីអេដស៍ខេត្ត។

**៩.បញ្ហានានា:**

- ការឧបត្ថម្ភប្រាក់លើកទឹកចិត្ត យឺត ។
- ការប្រើប្រាស់ស្រោមអនាម័យកន្លងមកមិនគ្រប់គ្រាន់ទេចំពោះអ្នកផ្ទុកមេរោគអេដស៍ សំណូមពរសុំ ១០ ស្រោម ទើបប្រើគ្រាន់ ។
- ការដាក់អោយដំណើរការសកម្មភាពនេះ ហាក់ដូចជាបន្ថែមការងារថ្មីដល់ក្រុមគាត់ទៀត ។

**១០.ចំណុចត្រូវតាមដាន និងសកម្មភាពបន្ត:**

- MCH ខេត្ត ដោយសហការណ៍ជាមួយ PASP ត្រូវជួយសំរបសំរួលផ្តល់ ឱសថពន្យាកំណើតដូចជា Pill Depo ដោយជួយវាយតំលៃពីតំរូវការជាក់ស្តែង ការប្រើប្រាស់ និង តាមដានផ្តល់បច្ចេកទេសដល់បុគ្គលិក OI/ART បន្ថែមទៀត តាមរយៈការចុះអភិបាល រួមពីកម្មវិធីអេដស៍ ខេត្តដោយប្រើប្រាស់ថវិកាមូនិធិសកល ។
- ឱសថពន្យាកំណើតត្រូវបានស្នើសុំពីមណ្ឌលសុខភាពព្រែកខ្សាយ ខ ដែលនៅជិតដោយប្រើប្រាស់បណ្តោះអាសន្នមួយរយៈពេលសិន ។
- បុគ្គលិក OI/ART សំណូមពរសុំបញ្ចូលឱសថពន្យាកំណើតទៅក្នុងកញ្ចប់ CMSដែលផ្តល់ដោយ ផ្ទាល់ដល់ក្រុម OI/ART នៃមន្ទីរពេទ្យខេត្ត តាមរយៈស្រុកប្រតិបត្តិអ្នកលឿង។

**១១.សេចក្តីសន្និដ្ឋាន:**

វគ្គសិក្ខាសាលាតំរង់ទិស និង បណ្តុះបណ្តាលការបង្ការជាវិជ្ជមាន និង ការផ្តល់សេវាពន្យាកំណើតសំរាប់ បុគ្គលិកសេវាព្យាបាលជំងឺឱកាសនិយម និង ឱសថប្រឆាំងមេរោគអេដស៍បានដំណើរប្រកប ទៅដោយជោគជ័យក្រោមការប្រកាសបិទដោយលោកសាស្ត្រាចារ្យ **កេត លីសុត្ថា** អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក និងលោកវេជ្ជ **សេង វុធី** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធ និង ជំងឺអេដស៍ សើស្បែក និងកាមរោគក្រោមការប្តេជ្ញាចិត្តរបស់ក្រុម OI/ART ថាដំណើរការអនុវត្តសកម្មភាពបង្ការជាវិជ្ជមានចាប់ពីខែកញ្ញា ឆ្នាំ ២០១១នេះ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១

បានឃើញ និង ឯកភាព

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ

នឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

អនុប្រធាន

វេជ្ជ.ល. ពេញ ស៊ុន

អ្នកធ្វើរបាយការណ៍

លោក កែវ វណ្ណៈ